**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសុខាភិបាល**

## សេចក្តីជូនព័ត៌មានរបស់ក្រសួងសុខាភិបាល
## ស្តីពី
## ករណីព្យាបាលជាសះស្បើយ ០៤នាក់
## និងករណីវិជ្ជមានកូវីដ-១៩ ថ្មី ០១នាក់ នៅថ្ងៃទី០៩ ខែមេសា ឆ្នាំ២០២០

ក្រសួងសុខាភិបាល សូមគោរពជម្រាបជូនសាធារណជនទាំងអស់ឲ្យបានជ្រាបពីស្ថានភាពជំងឺកូវីដ-១៩ នៅកម្ពុជា មានដូចខាងក្រោមនេះ៖

**១. ស្ថានភាពជំងឺកូវីដ ១៩ នៅទូទាំងប្រទេស ៖**

ត្រឹមម៉ោង០៧:០០ព្រឹក ថ្ងៃទី១០ ខែមេសា ឆ្នាំ២០២០ ស្ថានភាពជំងឺកូវីដ-១៩ នៅកម្ពុជា មាន៖

- អ្នកព្យាបាលជាសះស្បើយ សរុបចំនួនកើនដល់ ៧២នាក់ (ស្មើនឹង ៦០,៥០% ធៀបនឹងចំនួនអ្នកមានវីរុសកូវីដ-១៩ទាំងអស់) ដែលមានបុរសជនជាតិចិន ០១នាក់ ស្ត្រីជនជាតិអង់គ្លេស ០៣នាក់ បុរសជនជាតិអង់គ្លេស ០១នាក់ បុរសជនជាតិបែលហ្សិក ០១នាក់ បុរសជនជាតិបារាំង ១២នាក់ (ក្នុងនេះមានទារកអាយុ ០៤ខែ) ស្ត្រីជនជាតិបារាំង ១២នាក់ បុរសជនជាតិម៉ាឡេស៊ី ០៨នាក់ បុរសជនជាតិខ្មែរ ៣០នាក់ និងស្ត្រីជនជាតិខ្មែរ ០៤នាក់ (គិតចាប់ពីខែមករាដល់បច្ចុប្បន្ននេះ)។
- អ្នកដែលកំពុងសម្រាកព្យាបាល សរុបចំនួន ៤៧នាក់ (ស្ត្រី ១៧នាក់ និងបុរស ៣០នាក់) នៅតាមមន្ទីរពេទ្យរដ្ឋនៅថ្នាក់ជាតិ និងថ្នាក់ខេត្ត
- អ្នកមានវីរុសកូវីដ-១៩ ដែលបានរកឃើញទាំងអស់ (រាប់ទាំងអ្នកដែលបានព្យាបាលជាសះស្បើយ និងអ្នកដែលកំពុងព្យាបាល) នៅទូទាំងប្រទេសសរុបចំនួន ១១៩នាក់ (ស្ត្រី ៣៦នាក់ និងបុរស ៨៣នាក់)។

**២. ករណីជាសះស្បើយ៖** មាន ០៤នាក់

- បុរសជនជាតិខ្មែរអាយុ ៥៩ឆ្នាំ ទីលំនៅ ភូមិបារ៉ែនក្រោម ឃុំស្វាយប្រទាល ស្រុកស្អាង ខេត្តកណ្តាល បានជាសះស្បើយ ដោយទទួលបានលទ្ធផលតេស្តអវិជ្ជមានចំនួន ០២លើក ត្រូវបានអនុញ្ញាតឲ្យចេញពីមន្ទីរពេទ្យខេត្តកណ្តាល។ បុរសរូបនេះ ជាអ្នកដែលបានប៉ះពាល់ផ្ទាល់ជាមួយបុរសអាយុ ៦០ឆ្នាំ (រស់នៅភូមិ/ឃុំជាមួយគ្នា) បានជាសះស្បើយត្រឡប់ទៅផ្ទះវិញរួចហើយ និងបានវិលត្រឡប់មកពីចូលរួមពិធីបុណ្យសាសនានៅប្រទេសម៉ាឡេស៊ី។
- បុរសជនជាតិខ្មែរអាយុ ៥៥ឆ្នាំ នៅស្រុកកងមាស ខេត្តកំពង់ចាម បានជាសះស្បើយដោយទទួលបានលទ្ធផលតេស្តអវិជ្ជមានចំនួន ០២លើក ត្រូវបានអនុញ្ញាតឲ្យចេញពីមន្ទីរពេទ្យខេត្តកំពង់ចាម។ បុរសរូបនេះ ជាកម្មករសម្អាតព្រះវិហារឥស្លាម និងជាអ្នកប៉ះពាល់ផ្ទាល់ជាមួយជនជាតិម៉ាឡេស៊ី។


ទីស្តីការក្រសួងសុខាភិបាល ផ្លូវលេខ ៨០ វិថីសម្តេចប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារ: (៨៥៥-២៣) ៨៨០ ...

- បុរសជនជាតិខ្មែរអាយុ ៣៥ឆ្នាំ នៅក្រុងព្រះវិហារ បានជាសះស្បើយដោយទទួលបានលទ្ធផលតេស្តអវិជ្ជមានចំនួន ០២លើក ត្រូវបានអនុញ្ញាតឲ្យចេញពីមន្ទីរពេទ្យខេត្តព្រះវិហារ។ បុរសរូបនេះ ជាអ្នកដែលបានវិលត្រឡប់មកពីការចូលរួមពិធីសាសនានៅប្រទេសម៉ាឡេស៊ី។

- បុរសជនជាតិម៉ាឡេស៊ីអាយុ ៥៨ឆ្នាំ ស្នាក់នៅបណ្តោះអាសន្ននៅក្រុងកែប បានជាសះស្បើយដោយទទួលបានលទ្ធផលតេស្តអវិជ្ជមានចំនួន ០២ដង ត្រូវបានអនុញ្ញាតឲ្យចេញពីមន្ទីរពេទ្យខេត្តកែប។ បុរសរូបនេះ មកធ្វើការងារសាសនានៅកម្ពុជា ដោយធ្វើដំណើរមកពីប្រទេសម៉ាឡេស៊ី។

**៣. ករណីកូវីដ-១៩ ថ្មី ៖** ០១នាក់

- ស្ត្រីជនជាតិវៀតណាមអាយុ ៣៩ឆ្នាំ ជាអ្នកទេសចរស្នាក់នៅខុនដូមួយកន្លែង ដែលស្ថិតនៅកោះពេជ្រ រាជធានីភ្នំពេញ។ ដោយទទួលលទ្ធតេស្តវិជ្ជមានវីរុសកូវីដ-១៩ ហើយស្ត្រីរូបនេះកំពុងសម្រាកព្យាបាលនៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត។

ក្រសួងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជាទីបំផុត ជូនដល់ថ្នាក់ដឹកនាំ មន្ត្រី-បុគ្គលិកសុខាភិបាល និងក្រុមគ្រូពេទ្យទាំងអស់នៅទូទាំងប្រទេស ស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធទាំងអស់ ទាំងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ អង្គការសុខភាពពិភពលោក មជ្ឈមណ្ឌលប្រយុទ្ធនឹងជំងឺឆ្លងសហរដ្ឋអាមេរិក និងវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា ដែលបានខិតខំបំពេញភារកិច្ចបានល្អប្រសើរបំផុត ក្នុងការជួយពិនិត្យសុខភាព និងស្រាវជ្រាវរកករណីកូវីដ១៩ ព្រមទាំងអ្នកប៉ះពាល់ទាំងអស់កន្លងមក រួមទាំងការដាក់វិធានការនានា ដើម្បីទប់ស្កាត់ការចម្លងវីរុសកូវីដ-១៩ នៅក្នុងប្រទេសកម្ពុជា។

ក្រសួងសុខាភិបាល បន្តជូនដំណឹងដល់សាធារណជនអំពីការវិវត្តន៍នៃបញ្ហាសុខភាព តាមទំព័រហ្វេសប៊ុក និងគេហទំព័ររបស់ក្រសួង www.cdcmoh.gov.kh ដែលគេហទំព័រនេះមានសម្ភារៈអប់រំសុខភាពដែលអាចទាញយកមកប្រើប្រាស់បាន។ សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមកទូរស័ព្ទទាន់ហេតុការណ៍ ក្រសួងសុខាភិបាល លេខ ១១៥ ដោយឥតគិតថ្លៃ ឬទំនាក់ទំនងក្រសួងសុខាភិបាល តាមលេខទូរស័ព្ទ៖ ០១២ ៨២៥ ៤២៤ ឬ ០១២ ៤៨៨ ៩៨១ ឬ ០១២ ៨៣៦ ៨៦៨ ។

ថ្ងៃសុក្រ ៣រោច ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី១០ ខែមេសា ឆ្នាំ២០២០



ទីស្ដីការក្រសួងសុខាភិបាល ដីឡូតិ៍លេខ ៨០ វិថីសម្ដេចប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារៈ (៨៥៥-២៣) ៨៨៥ ៩៧០ / ៨៨៤ ៩០៩